ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខ: ៤.៨២៨/ប្រក.ប.ស្ថ/០៦២៤

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកែសម្រួលប្រការ៣ នៃប្រកាសអន្តរក្រសួងលេខ១៩១ ប្រ.ក ប.ស្ថ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន** **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៩៧ សសរ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ



អគារមរតកតេជោ ដីឡូត៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

Scanned with CamScanner

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៧៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងបរិស្ថាន
- បានឃើញប្រកាសលេខ ០២១ ប្រ.ក ប.ស្ល ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍
- បានឃើញប្រកាសលេខ ៣៥៦ ប្រ.ក ប.ស្ល ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្ត លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- យោងការចាំបាច់របស់ក្រសួងបរិស្ថាន និងក្រសួងរ៉ែ និងថាមពល

**សម្រេច**

**ប្រការមួយ ..**

ប្រការ៣ នៃប្រកាសលេខ ១៩១ ប្រ.ក ប.ស្ល ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**ប្រការ ៣.. ថ្មី**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងធ្វើអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀត ដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច ដែលមានផ្ទៃដីសរុបតិចជាង ឬស្មើ ១(មួយ)ហិកតា ត្រូវមានត្រឹមកិច្ចសន្យាការពារបរិស្ថាន ដោយមានការឯកភាពជាផ្លូវការពីមន្ទីរបរិស្ថានរាជធានី ខេត្ត ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចេញអាជ្ញាបណ្ណធនធានរ៉ែដោយរដ្ឋបាលរាជធានី ខេត្ត ឬមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត លើកលែងតែប្រភេទគម្រោងមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម ដែលមន្ទីរបរិស្ថានរាជធានី ខេត្ត តម្រូវឱ្យមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង។ ប្រភេទគម្រោងស្ថិតក្នុងតំបន់ហាមឃាត់ដែលកំណត់ដោយមន្ទីរបរិស្ថាន និងមន្ទីររ៉ែនិងថាមពល រាជធានី ខេត្ត នឹងមិនត្រូវបានអនុញ្ញាតឡើយ។



Scanned with CamScanner

សុពលភាពនៃលិខិតឯកភាពលើកិច្ចសន្យាការពារបរិស្ថាន មានរយៈពេល ១(មួយ)ឆ្នាំ។

ចំពោះប្រភេទអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្ដៅដីចល័ត ដែលមានក្រឡាផ្ទៃមិនលើសពី ០,៥ហិកតា និងជម្រៅមិនលើសពី ៣ម៉ែត្រ ឬប្រតិបត្តិការបេកយកអាចម៍ដី ដែលមានក្រឡាផ្ទៃមិនលើសពី ១ហិកតា និងជម្រៅមិនលើសពី ១ម៉ែត្រ លើដីកម្មសិទ្ធិឯកជនស្របច្បាប់ ដែលចេញដោយរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ពុំតម្រូវឱ្យមានកិច្ចសន្យាការពារបរិស្ថានដែលចេញដោយមន្ទីរបរិស្ថានរាជធានី ខេត្តទេ ប៉ុន្តែតម្រូវឱ្យម្ចាស់អាជ្ញាបណ្ណត្រូវធ្វើលិខិតធានាអះអាងកិច្ចគាំពារបរិស្ថាន ដាក់ជូនរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ក្នុងពេលស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្ដៅដីចល័តដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ២ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ ..**

អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងបរិស្ថាន និងក្រសួងរ៉ែ និងថាមពល ព្រមទាំងគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**អ៊ាង សុផល្លែត**

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ រតនៈ**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



Scanned with CamScanner

**ឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៤៥៤/២៥ ប្រ.ក.ប.ស្ថ ថ្ងៃ ព្រហ... ៣ កើត ...... ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី ១៣ ... ខែ មិថុនា ... ឆ្នាំ២០២៥ ស្តីពីការកែសម្រួលប្រការ៣ នៃប្រកាសអន្តរក្រសួងលេខ១៩១ ប្រ.ក ប.ស្ថ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច**

**លិខិតធានាអះអាង**

**កិច្ចគាំពារបរិស្ថានលើការធ្វើអាជីវកម្មសិប្បកម្មធនធានរ៉ែ**

**សម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត**

ខ្ញុំឈ្មោះ.................................. ភេទ......... អាយុ........ ជនជាតិ........... អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ........................ មានសុពលភាពចុះថ្ងៃទី...... ខែ........ ឆ្នាំ......... ផុតសុពលភាពថ្ងៃទី...... ខែ........ ឆ្នាំ......... លេខទូរស័ព្ទ....................... មានទីលំនៅបច្ចុប្បន្នភូមិ............... សង្កាត់/ឃុំ.................... ក្រុង/ស្រុក/ខណ្ឌ ................... រាជធានី/ខេត្ត.................. មានបំណងស្នើសុំធ្វើអាជីវកម្មសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត ដែលមានទីតាំងស្ថិតនៅក្រុង/ស្រុក/ខណ្ឌ..................... ខេត្ត............................។

**សូមគោរពជូន**

**លោក/លោកស្រី អភិបាល នៃគណៈអភិបាលក្រុង/ស្រុក/ខណ្ឌ.............................**

ដើម្បីចូលរួមចំណែក និងធានាបាននូវនិរន្តរភាពបរិស្ថាន ក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ខ្ញុំសូមធានាអះអាងកិច្ចគាំពារបរិស្ថានដែលពាក់ព័ន្ធនឹងការធ្វើសេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត ដែលមានក្រឡាផ្ទៃមិនលើសពី ០,៥ហិកតា និងជម្រៅមិនលើសពី ៣ម៉ែត្រ ឬប្រតិបត្តិការបកយកអាចម៍ដី ដែលមានក្រឡាផ្ទៃមិនលើសពី ១ហិកតា និងជម្រៅមិនលើសពី ១ម៉ែត្រ របស់ខ្ញុំ ដែលមានទីតាំងស្ថិតនៅក្រុង/ស្រុក/ខណ្ឌ ..................... ខាងលើ ដូចខាងក្រោម៖

១. ធានាអនុវត្តតាមគោលការណ៍ណែនាំរបស់មន្ទីរបរិស្ថានក្នុងកិច្ចគាំពារបរិស្ថានក្នុងបរិវេណ និងជុំវិញបរិវេណនៃទីតាំងជីកអាចម៍ដី រណ្តៅដីចល័ត មានដូចតទៅ៖
   - ធ្វើអាជីវកម្មជីកយកអាចម៍ដី រណ្តៅដីចល័ត គឺនៅលើដីកម្មសិទ្ធិឯកជនស្របច្បាប់
   - មិនធ្វើឱ្យមានផលប៉ះពាល់ដល់ទីសាធារណៈ ទីសក្ការបូជា និងតំបន់បេតិកភណ្ឌជាតិជាដើម
   - ជីកអាចម៍ដីត្រូវអនុវត្តតាមបច្ចេកទេសមិនបណ្តាលឱ្យបាក់ដី ឬប៉ះពាល់ដល់ព្រំដី ឬទ្រព្យសម្បត្តិអ្នកជិតខាង
   - ធ្វើការដឹកជញ្ជូនអាចម៍ដី ត្រូវប្រើគម្របការពារដីហុយធូលី ឬជ្រុះអាចម៍ដីដែលធ្វើឱ្យប៉ះពាល់ដល់អ្នកធ្វើដំណើរ



Scanned with CamScanner

- ធានាកាត់បន្ថយការរំខានដោយសំឡេង និងរំញ័រដែលធ្វើឱ្យប៉ះពាល់ដល់អ្នកជិតខាង
- ជួយរក្សាអនាម័យ និងគ្រប់គ្រងសំណល់រឹង និងសំណល់រាវ នៅលើទីតាំងជីកអាចម៍ដី រណ្តៅដីចល័ត
- ធានាទុកដាក់ និងគ្រប់គ្រងឱ្យបានល្អ ចំពោះប្រេងឥន្ធនៈដែលបម្រើឱ្យគ្រឿងចក្រ និងសំណល់ប្រេងម៉ាស៊ីនរបស់គ្រឿងចក្រ ចៀសវាងការកំពប់ ឬបោះបង់ចោល/បង្ហូរទៅក្នុងប្រភពទឹក ឬលើដីដែលនាំឱ្យមានផលប៉ះពាល់ដល់គុណភាពទឹក ដី និងជីវៈចម្រុះ
- ចូលរួមការពារថែរក្សាផ្លូវ ដែលពាក់ព័ន្ធនឹងការប្រកបអាជីវកម្មជីកជញ្ជូនអាចម៍ដី
- ទទួលយកយោបល់រិះគន់របស់សហគមន៍មូលដ្ឋាន ដើម្បីធ្វើការកែលម្អនូវចំណុចខ្វះខាត
- ទទួលខុសត្រូវចំពោះមុខច្បាប់ចំពោះករណីមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្សជាយថាហេតុនៅទីតាំងការដ្ឋាន
- ធានារៀបចំឱ្យមានសណ្តាប់ធ្នាប់ប្រកបដោយសុវត្ថិភាព និងសោភ័ណភាពបរិស្ថានឱ្យបានត្រឹមត្រូវនៅពេលបញ្ចប់ការធ្វើអាជីវកម្មជីកយកអាចម៍ដី រណ្តៅដីចល័ត។

២.. បង្កលក្ខណៈ និងផ្តល់កិច្ចសហការដល់មន្ត្រីជំនាញនៃមន្ទីរបរិស្ថានរាជធានី ខេត្ត ដែលមានបេសកកម្មត្រឹមត្រូវ ដើម្បីត្រួតពិនិត្យ និងធ្វើអធិការកិច្ចនៅទីតាំងអាជីវកម្មរបស់ខ្ញុំ។

៣.. ក្នុងករណី ដែលខ្ញុំពុំគោរពតាមប្រការណាមួយ ឬអនុវត្តផ្ទុយពីការធានាខាងលើនេះ ខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃ................. ខែ............ ឆ្នាំ........... ព.ស.២៥......

ធ្វើនៅ......................ថ្ងៃទី........ ខែ............... ឆ្នាំ២០.....

**ស្នាមមេដៃ និងឈ្មោះសាមីខ្លួន**

បានឃើញ និងបញ្ជាក់ថា

ស្នាមមេដៃពិតជារបស់សាមីខ្លួនប្រាកដមែន

លេខ៖.....................................

ថ្ងៃទី...............ខែ..............ឆ្នាំ២០.........

**អភិបាលនៃគណៈអភិបាលក្រុង/ស្រុក/ខណ្ឌ**.................



Scanned with CamScanner